ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣✻៨

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ៣៦៥ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពី

## របៀបឧបត្ថម្ភសំរាប់មណ្ឌលជីវិតថ្មីភ្នំបាត់

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០១ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៥អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ៣៥៩ ស.អ.យ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត-ក្រុង
- បានឃើញប្រកាសលេខ ២៥០ ស.អ.យ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតមជ្ឈមណ្ឌល ជីវិតថ្មីភ្នំបាត់
- បានឃើញប្រកាសលេខ ២៥១ ស.អ.យ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជីវិតថ្មីភ្នំបាត់
- បានឃើញសេចក្តីសំរេចលេខ ៥៥ សសរ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីការកែសំរួលនិងបំពេញបន្ថែមប្រាក់ឧបត្ថម្ភចំពោះទារកកំព្រា កុមារកំព្រា ជនជរាពិការ ស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ

- ពិនិត្យឃើញការចាំបាច់របស់ក្រសួង

**សម្រេច**

**ប្រការ ១.-** ប្រកាសនេះ មានគោលបំណងកំណត់អំពីរបបឧបត្ថម្ភ ប្រចាំថ្ងៃ សំរាប់មជ្ឈមណ្ឌល **ជីវិតថ្មីភ្នំបាក់** ។

**ប្រការ ២.-** មជ្ឈមណ្ឌល **ជីវិតថ្មីភ្នំបាក់** ត្រូវអនុវត្តរបបឧបត្ថម្ភប្រចាំថ្ងៃ តាមសេចក្តីសំរេចលេខ ៥៥ សសរ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩២ របស់ក្រុមប្រឹក្សា រដ្ឋមន្ត្រី ស្តីពីការកែសំរួលនិងបំពេញបន្ថែម ប្រាក់ឧបត្ថម្ភចំពោះទារកកំព្រា កុមារកំព្រា ជនជរាពិការ ស្នាក់នៅក្នុងមជ្ឈមណ្ឌលសង្គ្រោះ របស់រដ្ឋ ។

**ប្រការ ៣.-** មជ្ឈមណ្ឌល**ជីវិតថ្មីភ្នំបាក់** អាចទទួលយកវិភាគទាន ពីក្រុមគ្រួសារ ឬអ្នកអាណាព្យាបាលនៃជនរងគ្រោះទៅតាមលទ្ធភាព ដើម្បីជាប្រយោជន៍ដល់ដំណើរការ និងអភិវឌ្ឍន៍មណ្ឌល ។

**ប្រការ ៤.-** មន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ មានភារកិច្ចគ្រប់គ្រងការប្រើប្រាស់ថវិកានេះ តាមបទប្បញ្ញត្តិជាធរមាន និងដោយតម្លាភាព ។

**ប្រការ ៥.-** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋាន បច្ចេកទេស ប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានយុវនីតិសម្បទា ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត បន្ទាយមានជ័យ និងប្រធានមជ្ឈមណ្ឌល ជីវិតថ្មីភ្នំបាក់ មានភារកិច្ចរៀងៗខ្លួន អនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងការពារជាតិ
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងយុត្តិធម៌
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ខៀវ សាញ់**
-អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
-សាលាខេត្តបន្ទាយមានជ័យ "ដើម្បីជូនជ្រាប"
-ដូចប្រការ៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ